អាលម៉ា ៥–៧
ថ្ងៃទី ១–៧ ខែ មិថុនា

# តើសំណួររបស់អាលម៉ាជួយយើងឲ្យរីកចម្រើនខាងវិញ្ញាណដោយរបៀបណា ?



## តើការបង្រៀនខ្ញុំយ៉ាងណាដែរ ?

អាលម៉ាបានសួរដល់ប្រជាជននៃសារ៉ាហិមឡា ៣៦ សំណួរ ដើម្បីជួយពួកគេឲ្យធ្វើការវាយតម្លៃលើការរីកចម្រើនខាងវិញ្ញាណរបស់ពួកគេ ។ ប្រធាន អិម រ័សុល បាឡឺដ ប្រធានស្ដីទីក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានពន្យល់ថា ការវាយតម្លៃខាងវិញ្ញាណគឺមានប្រយោជន៍ ។ លោកបានមានប្រសាសន៍ថា « ជាការណែនាំដល់ខ្ញុំអំឡុងពេល [ ការវាយតម្លៃ ] នេះ ខ្ញុំចូលចិត្តអាន ហើយពិចារណាអំពីពាក្យពេចន៍ដែលធ្វើឲ្យពិចារណាអំពីខ្លួនឯងដែលមាននៅក្នុងអាលម៉ា ជំពូកទីប្រាំ » ។[១]

## តើខ្ញុំត្រូវផ្លាស់ប្ដូរអ្វីខ្លះ ?

នៅពេលអ្នកអាន អាលម៉ា ៥:៣–១៣ សូមរកមើលនូវអ្វីដែលអាលម៉ាបានបង្រៀនអំពីរបៀបដែលយើងអាចផ្លាស់ប្ដូរ និងខិតកាន់តែជិតព្រះគ្រីស្ទ ។ សូមពិចារណាថាអ្វីខ្លះដែលអ្នកអាចផ្លាស់ប្ដូរបាន ហើយដាក់ផែនការដើម្បីធ្វើវា ។

## តើព្រះអម្ចាស់បានប្រទានពរដល់ខ្ញុំដោយរបៀបណា ?

អាលម៉ាក៏បានអញ្ជើញប្រជាជនឲ្យចងចាំពីរបៀបដែលព្រះអម្ចាស់បានដោះលែងបុព្វការីជនរបស់ពួកគេ និងឲ្យពួកគេរំឭកពីការប្រែចិត្តជឿរបស់ពួកគេ ។ សូមពិចារណាពីការសរសេររឿងនៃការប្រែចិត្តជឿរបស់អ្នក ដើម្បីចងចាំពីរបៀបដែលព្រះអម្ចាស់បានប្រទានពរដល់អ្នក ។ អ្នកក៏អាចអានរឿងរ៉ាវនៃការប្រែចិត្តជឿរបស់បុព្វការីជនរបស់អ្នក ឬរបស់សមាជិកសាសនាចក្រពីដើម ។

« វាជាការណ៍ប្រសើរណាស់ បើពួកបរិសុទ្ធគ្រប់គ្នាបានដឹងពីរឿងនៃការប្រែចិត្តជឿរបស់ដូនតាគេ ។ . . . យើងម្នាក់ៗនឹងមានពរជ័យយ៉ាងមហិមា បើយើងដឹងពីរឿងនៃសេចក្ដីជំនឿ និង ការលះបង់ ដែលនាំឲ្យដូនតាយើងចូលរួមក្នុងសាសនាចក្ររបស់ព្រះអម្ចាស់ » ។[២]

កំណត់ចំណាំ
១. អិម រ៉ាសុល បាឡឺត « Return and Receive » *Liahona* ខែ ឧសភា ឆ្នាំ ២០១៧ ទំព័រ ៦៤ ។
២. វីល្លាម អរ វ៉កឃើរ « Live True to the Faith » *Liahona* ខែ ឧសភា ឆ្នាំ ២០១៤ ទំព័រ ៩៧, ៩៩ ។